
ឧបសម្ព័ន្ធ

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

**បញ្ជីរាយនាមសេវា**

យោង ប្រកាសលេខ ប្រក.សក ចុះថ្ងៃទី ខែ ឆ្នាំ២០១០

ស្តីពីការធ្វើប្រតិភូកម្មអំណាចរដ្ឋបាលកណ្តាល ពីក្រសួងសាធារណការនិងដឹកជញ្ជូនជូនរដ្ឋបាល ចតុកោណ-ទូល តែមួយរបស់

ក្រុងតាខ្មៅនៃខេត្តកណ្តាល ស្រុកពាមរក៍នៃខេត្តព្រៃវែង ក្រុងសួងនៃខេត្តកំពង់ចាម ក្រុងក្រចេះនៃខេត្តក្រចេះ ក្រុងស្ទឹងសែននៃខេត្តកំពង់ធំ

ក្រុងប៉ោយប៉ែតនៃខេត្តបន្ទាយមានជ័យ និងក្រុងព្រះសីហនុនៃខេត្តព្រះសីហនុ

| ល.រ | សេវាកម្មសាធារណៈ | ថ្នាក់ដែលកំពង់សំរេច | | | | ថ្នាក់ដែលនឹងធ្វើការសំរេច | | | លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ | ផ្សេងៗ ដែលពាក់ព័ន្ធអាជ្ញាធរមូលដ្ឋាន |
|---|---|---|---|---|---|---|---|---|---|---|
| | | ក្រសួង | ខេត្ត-ក្រុង | ស្រុក | ឃុំ | ខេត្ត-ក្រុង | ស្រុក | ឃុំ | | |
| ១ | ចុះបញ្ជីទោចក្រយានយន្ត ត្រីចក្រយាន ត្រីចក្រយានយន្តដែលម្ចាស់មានអាស័យដ្ឋាននៅក្នុងក្រុងតាខ្មៅ ស្រុកពាមរក៍ ក្រុងសួង ក្រុងក្រចេះ ស្រុកស្ទឹងសែន ក្រុងប៉ោយប៉ែត និងក្រុងព្រះសីហនុ | X | X | | | | X | | ១-បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៧/០០៧ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីចរាចរលើផ្លូវគោក | |
| ២ | ចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនក្នុងរង្វង់ ក្រុងតាខ្មៅ ស្រុកពាមរក៍ ក្រុងសួង ក្រុងក្រចេះ ស្រុកស្ទឹងសែន ក្រុងប៉ោយប៉ែតនិងក្រុងព្រះសីហនុ:<br>-ត្រីចក្រយាន ត្រីចក្រយានយន្ត<br>-ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក<br>-ទោចក្រយានសណ្តោងរ៉ឺម៉ក | X | X | | | | X | | ២-អនុក្រឹត្យ លេខ៧៧អនក្រ បក ចុះថ្ងៃទី ២៨ខែវិច្ឆិកា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាលកម្ពុជា<br>៣-សារាចរណែនាំលេខ ០០១ សក សរ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ចុះថ្ងៃទី ១៤-០១-២០០៤ | |

# ឧបសម្ព័ន្ធទី ២

យោង សេចក្តីណែនាំលេខ សក.សណន ចុះថ្ងៃទី ខែ ឆ្នាំ ២០១០

លើការអនុវត្តន៍ប្រកាសស្តីពីការធ្វើប្រតិភូកម្មអំណាចរដ្ឋបាលកណ្តាល

ពីក្រសួងសាធារណការ និងដឹកជញ្ជូន

| លេខ | ម្ចាស់កម្មសិទ្ធិ | | ម៉ាក | ប្រភេទ | លេខម៉ាស៊ីន | លេខតួ | សៀវភៅពន្ធ | ចំនួនស៊ីឡាំង | ផ្សេង |
|---|---|---|---|---|---|---|---|---|---|
| | | | ពណ៌ | កំលាំងសេះ | | លេខសាក់ស៊ី | បង្កាន់ដៃពន្ធ | ទំហំស៊ីឡាំង | |
| | | | | | | | លតាប័ត្រ | ចំនួនភ្លៅ | |
| ព្រះសីហនុ 1A-0002 | ផ្ទះ | ផ្លូវ | | | | | | | |
| | ក្រុម | ភូមិ | | | | | | | |
| | ឃុំ/សង្កាត់ | | | | | | | | |
| | ស្រុក/ខណ្ឌ | | | | | | | | |
| ព្រះសីហនុ 1A-0002 | ឈ្មោះ | | | | | | | | |
| | ផ្ទះ | ផ្លូវ | | | | | | | |
| | ក្រុម | ភូមិ | | | | | | | |
| | ឃុំ/សង្កាត់ | | | | | | | | |
| | ស្រុក/ខណ្ឌ | | | | | | | | |
| ព្រះសីហនុ 1A-0002 | ឈ្មោះ | | | | | | | | |
| | ផ្ទះ | ផ្លូវ | | | | | | | |
| | ក្រុម | ភូមិ | | | | | | | |
| | ឃុំ/សង្កាត់ | | | | | | | | |
| | ស្រុក/ខណ្ឌ | | | | | | | | |

# ឧបសម្ព័ន្ធទី ២

យោង សេចក្តីណែនាំលេខ សក.សណន ចុះថ្ងៃទី ខែ ឆ្នាំ ២០១០

លើការអនុវត្តន៍ប្រកាសស្តីពីការធ្វើប្រតិភូកម្មអំណាចរដ្ឋបាលកណ្តាល

ពីក្រសួងសាធារណការ និងដឹកជញ្ជូន

| លេខ | ម្ចាស់កម្មសិទ្ធិ | ម៉ាក | ប្រភេទ | លេខម៉ាស៊ីន | លេខតួ | សៀវភៅពន្ធ | ចំនួនស៊ីឡាំង | ផ្សេង |
|---|---|---|---|---|---|---|---|---|
| | | ពណ៌ | កំលាំងសេះ | | លេខសាក់ស៊ី | បង្កាន់ដៃពន្ធ | ទំហំស៊ីឡាំង | |
| | | | | | | លតាប័ត្រ | ចំនួនភ្លៅ | |
| ព្រៃវែង 1A-0002 | ផ្ទះ ផ្លូវ | | | | | | | |
| | ក្រុម ភូមិ | | | | | | | |
| | ឃុំ/សង្កាត់ | | | | | | | |
| | ស្រុក/ខណ្ឌ | | | | | | | |
| ព្រៃវែង 1A-0002 | ឈ្មោះ | | | | | | | |
| | ផ្ទះ ផ្លូវ | | | | | | | |
| | ក្រុម ភូមិ | | | | | | | |
| | ឃុំ/សង្កាត់ | | | | | | | |
| | ស្រុក/ខណ្ឌ | | | | | | | |
| ព្រៃវែង 1A-0003 | ឈ្មោះ | | | | | | | |
| | ផ្ទះ ផ្លូវ | | | | | | | |
| | ក្រុម ភូមិ | | | | | | | |
| | ឃុំ/សង្កាត់ | | | | | | | |
| | ស្រុក/ខណ្ឌ | | | | | | | |

## ឧបសម្ព័ន្ធទី ១

យោង សេចក្តីណែនាំលេខ សក.សណន ចុះថ្ងៃទី ខែ ឆ្នាំ ២០១០

លើការអនុវត្តន៍ប្រកាសស្តីពីការធ្វើប្រតិភូកម្មអំណាចរដ្ឋបាលកណ្តាលពីក្រសួងសាធារណការ និងដឹកជញ្ជូន

| តែមប្រើសារពើពន្ធ |
|---|

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ផ្លាក់លេខ............................

លេខសៀវភៅពន្ធ...................

លេខបង្កាន់ដៃពន្ធ...................

### ពាក្យសុំប័ណ្ណសម្គាល់យានយន្ត

ខ្ញុំឈ្មោះ..............................................ភេទ................អាយុ............ឆ្នាំ ជនជាតិ.................................

សញ្ជាតិ............................ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ..................ផ្លូវលេខ.......................ក្រុម..........................

ភូមិ...........................ឃុំ-សង្កាត់............................. ក្រុង -ស្រុក..........................ខេត្ត ................................

អត្តសញ្ញាណប័ណ្ណ ឬ ប័ណ្ណគ្រួសារ................................................មុខរបរ........................................................

**សូ ម គោ រ ព ជូ ន**

**លោកអភិបាលក្រុង -ស្រុក**

**កម្មវត្ថុ :** សំណើសុំប័ណ្ណសម្គាល់....................ដោយខ្ញុំបាទ-នាងខ្ញុំទើបទិញ..........មួយគ្រឿង ដែលមានភិនភាគៈ

ម៉ាក់............................................................. កម្លាំងសេះ...............................................

ប្រភេទ.......................................................... ទម្ងន់ទទេ..................................................

ពណ៌............................................................. ទម្ងន់ ឬចំណុះផ្ទុក.......................................

| លេខម៉ាស៊ីន | លេខតួ | លេខសាក់ស៊ី |
|---|---|---|
| | | |

យានយន្តនេះពុំទាន់មានប័ណ្ណសម្គាល់នៅឡើយ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **លោកអភិបាលក្រុង -ស្រុក** មេត្តាផ្តល់ប័ណ្ណសម្គាល់ យានយន្តដល់ខ្ញុំបាទ-នាងខ្ញុំ ដោយអនុគ្រោះ ។

សូម **លោកអភិបាលក្រុង -ស្រុក** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

.................ថ្ងៃទី..........ខែ.............ឆ្នាំ ២០១......

**ហត្ថលេខា**

**ភ្ជាប់មកជាមួយ**

- វិក័យប័ត្រ ឬ លិខិតលក់ ឬ លិខិតអំណោយ ០១ច្បាប់
- បង្កាន់ដៃពន្ធនាំចូល ០១ច្បាប់
- អត្តសញ្ញាណប័ណ្ណ ឬ ប័ណ្ណគ្រួសារ ០១ច្បាប់

# ឧបសម្ព័ន្ធទី ២

យោង សេចក្តីណែនាំលេខ សក.សណន ចុះថ្ងៃទី ខែ ឆ្នាំ ២០១០

លើការអនុវត្តន៍ប្រកាសស្តីពីការធ្វើប្រតិភូកម្មអំណាចរដ្ឋបាលកណ្តាល

ពីក្រសួងសាធារណការ និងដឹកជញ្ជូន

| លេខ | ម្ចាស់កម្មសិទ្ធិ | ម៉ាក | ប្រភេទ | លេខម៉ាស៊ីន | លេខតួ | សៀវភៅពន្ធ | ចំនួនស៊ីឡាំង | ផ្សេង |
|---|---|---|---|---|---|---|---|---|
| | | ពណ៌ | កំលាំងសេះ | | លេខសាក់ស៊ី | បង្កាន់ដៃពន្ធ | ទំហំស៊ីឡាំង | |
| | | | | | | លតាប័ត្រ | ចំនួនភ្លៅ | |
| កំពង់ចាម 1A-0002 | ផ្ទះ ផ្លូវ | | | | | | | |
| | ក្រុម ភូមិ | | | | | | | |
| | ឃុំ/សង្កាត់ | | | | | | | |
| | ស្រុក/ខណ្ឌ | | | | | | | |
| កំពង់ចាម 1A-0002 | ឈ្មោះ | | | | | | | |
| | ផ្ទះ ផ្លូវ | | | | | | | |
| | ក្រុម ភូមិ | | | | | | | |
| | ឃុំ/សង្កាត់ | | | | | | | |
| | ស្រុក/ខណ្ឌ | | | | | | | |
| កំពង់ចាម 1A-0002 | ឈ្មោះ | | | | | | | |
| | ផ្ទះ ផ្លូវ | | | | | | | |
| | ក្រុម ភូមិ | | | | | | | |
| | ឃុំ/សង្កាត់ | | | | | | | |
| | ស្រុក/ខណ្ឌ | | | | | | | |

# ឧបសម្ព័ន្ធទី ២

យោង សេចក្ដីណែនាំលេខ សក.សណន ចុះថ្ងៃទី ខែ ឆ្នាំ ២០១០

លើការអនុវត្តន៍ប្រកាសស្ដីពីការធ្វើប្រតិភូកម្មអំណាចរដ្ឋបាលកណ្ដាល

ពីក្រសួងសាធារណការ និងដឹកជញ្ជូន

| លេខ | ម្ចាស់កម្មសិទ្ធិ | ម៉ាក | ប្រភេទ | លេខម៉ាស៊ីន | លេខតួ | សៀវភៅពន្ធ | ចំនួនស៊ីឡាំង | ផ្សេង |
|---|---|---|---|---|---|---|---|---|
| | | ពណ៌ | កំលាំងសេះ | | លេខសាក់ស៊ី | បង្កាន់ដៃពន្ធ | ទំហំស៊ីឡាំង | |
| | | | | | | លតាប័ត្រ | ចំនួនភ្លៅ | |
| ក្រចេះ<br>1A-0002 | ផ្ទះ ផ្លូវ | | | | | | | |
| | ក្រុម ភូមិ | | | | | | | |
| | ឃុំ/សង្កាត់ | | | | | | | |
| | ស្រុក/ខណ្ឌ | | | | | | | |
| ក្រចេះ<br>1A-0002 | ឈ្មោះ | | | | | | | |
| | ផ្ទះ ផ្លូវ | | | | | | | |
| | ក្រុម ភូមិ | | | | | | | |
| | ឃុំ/សង្កាត់ | | | | | | | |
| | ស្រុក/ខណ្ឌ | | | | | | | |
| ក្រចេះ<br>1A-0002 | ឈ្មោះ | | | | | | | |
| | ផ្ទះ ផ្លូវ | | | | | | | |
| | ក្រុម ភូមិ | | | | | | | |
| | ឃុំ/សង្កាត់ | | | | | | | |
| | ស្រុក/ខណ្ឌ | | | | | | | |

# ឧបសម្ព័ន្ធទី ២

យោង សេចក្តីណែនាំលេខ សក.សណន ចុះថ្ងៃទី ខែ ឆ្នាំ ២០១០

លើការអនុវត្តន៍ប្រកាសស្តីពីការធ្វើប្រតិភូកម្មអំណាចរដ្ឋបាលកណ្តាល

ពីក្រសួងសាធារណការ និងដឹកជញ្ជូន

| លេខ | ម្ចាស់កម្មសិទ្ធិ | ម៉ាក | ប្រភេទ | លេខម៉ាស៊ីន | លេខតួ | សៀវភៅពន្ធ | ចំនួនស៊ីឡាំង | ផ្សេង |
|---|---|---|---|---|---|---|---|---|
| | | ពណ៌ | កំលាំងសេះ | | លេខសាក់ស៊ី | បង្កាន់ដៃពន្ធ | ទំហំស៊ីឡាំង | |
| | | | | | | លតាប័ត្រ | ចំនួនភ្លៅ | |
| បន្ទាយមានជ័យ 1A-0002 | ផ្ទះ ផ្លូវ | | | | | | | |
| | ក្រុម ភូមិ | | | | | | | |
| | ឃុំ/សង្កាត់ | | | | | | | |
| | ស្រុក/ខណ្ឌ | | | | | | | |
| បន្ទាយមានជ័យ 1A-0002 | ឈ្មោះ | | | | | | | |
| | ផ្ទះ ផ្លូវ | | | | | | | |
| | ក្រុម ភូមិ | | | | | | | |
| | ឃុំ/សង្កាត់ | | | | | | | |
| | ស្រុក/ខណ្ឌ | | | | | | | |
| បន្ទាយមានជ័យ 1A-0002 | ឈ្មោះ | | | | | | | |
| | ផ្ទះ ផ្លូវ | | | | | | | |
| | ក្រុម ភូមិ | | | | | | | |
| | ឃុំ/សង្កាត់ | | | | | | | |
| | ស្រុក/ខណ្ឌ | | | | | | | |

# ឧបសម្ព័ន្ធទី ២

យោង សេចក្តីណែនាំលេខ សក.សណន ចុះថ្ងៃទី ខែ ឆ្នាំ ២០១០

លើការអនុវត្តន៍ប្រកាសស្តីពីការធ្វើប្រតិភូកម្មអំណាចរដ្ឋបាលកណ្តាល

ពីក្រសួងសាធារណការ និងដឹកជញ្ជូន

| លេខ | ម្ចាស់កម្មសិទ្ធិ | ម៉ាក | ប្រភេទ | លេខម៉ាស៊ីន | លេខតួ | សៀវភៅពន្ធ | ចំនួនស៊ីឡាំង | ផ្សេង |
|---|---|---|---|---|---|---|---|---|
| | | ពណ៌ | កំលាំងសេះ | | លេខសាក់ស៊ី | បង្កាន់ដៃពន្ធ | ទំហំស៊ីឡាំង | |
| | | | | | | លតាប័ត្រ | ចំនួនភ្លៅ | |
| កំពង់ធំ 1A-0002 | ផ្ទះ ផ្លូវ | | | | | | | |
| | ក្រុម ភូមិ | | | | | | | |
| | ឃុំ/សង្កាត់ | | | | | | | |
| | ស្រុក/ខណ្ឌ | | | | | | | |
| កំពង់ធំ 1A-0002 | ឈ្មោះ | | | | | | | |
| | ផ្ទះ ផ្លូវ | | | | | | | |
| | ក្រុម ភូមិ | | | | | | | |
| | ឃុំ/សង្កាត់ | | | | | | | |
| | ស្រុក/ខណ្ឌ | | | | | | | |
| កំពង់ធំ 1A-0002 | ឈ្មោះ | | | | | | | |
| | ផ្ទះ ផ្លូវ | | | | | | | |
| | ក្រុម ភូមិ | | | | | | | |
| | ឃុំ/សង្កាត់ | | | | | | | |
| | ស្រុក/ខណ្ឌ | | | | | | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី៣

ខេត្ត ..............................................

សាលាស្រុក ..................................

លេខ ............................

## បញ្ជីរាយនាមអ្នកស្នើសុំធ្វើបណ្ណសម្គាល់គោយន្តយន្ត

| ល.រ N° | ផ្លាកលេខ PlateN° | ម៉ាក Mark/Model | ពណ៌ Color | ប្រភេទ Vehicle Type | កំលាំងសេះ HP | ចំ.អក្ស Axles N° | ចំ.ស៊ីឡាំង Cylin. N° | ទំហំស៊ីឡាំង Cylin.Disk CC | លេខម៉ាស៊ីន Engine N° | លេខតួ Body N° | លេខសាក់ស៊ី Chasiss N° | ឆ្នាំផលិត M.Year | ព័ត៌មានម្ចាស់កម្មសិទ្ធិ Owner Name | ប្រាក់ ចំនួន | សៀវភៅពន្ធ សន្លឹកពន្ធ | លេខលតាប័ត្រ ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | | | | | | | | | | | | | | | | |
| 2 | | | | | | | | | | | | | | | | |
| 3 | | | | | | | | | | | | | | | | |
| 4 | | | | | | | | | | | | | | | | |
| 5 | | | | | | | | | | | | | | | | |
| 6 | | | | | | | | | | | | | | | | |
| 7 | | | | | | | | | | | | | | | | |
| 8 | | | | | | | | | | | | | | | | |
| 9 | | | | | | | | | | | | | | | | |
| 10 | | | | | | | | | | | | | | | | |

-បានបញ្ចប់បញ្ជីនេះត្រឹមលេខរៀងទី 10 គ្រឿង
បានឃើញ និង ឯកភាព
....................ថ្ងៃទី.........ខែ.................ឆ្នាំ២០១....
គណៈអភិបាលស្រុក............................................

បានឃើញ និងពិនិត្យត្រឹមត្រូវ
............ថ្ងៃទី.........ខែ.................ឆ្នាំ២០១....
ប្រធានការិយាល័យច្រកចេញ-ចូលតែមួយ

បានពិនិត្យត្រឹមត្រូវ
............ថ្ងៃទី.........ខែ.................ឆ្នាំ២០១....
មន្ត្រីចុះបញ្ជីយានយន្ត

## ឧបសម្ព័ន្ធទី ៤

យោង សេចក្តីណែនាំលេខ ប្រកសណន ចុះថ្ងៃទី ខែ ឆ្នាំ ២០១០

លើការអនុវត្តន៍ប្រកាសស្តីពីការផ្ទេរប្រតិភូកម្មអំណាចរដ្ឋបាលកណ្តាលពីក្រសួងសាធារណការ និងដឹកជញ្ជូន

តែមប្រិសារពើពន្ធ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យសុំលិខិតអនុញ្ញាតយានយន្តធ្វើអាជីវកម្មដឹកជញ្ជូន

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ......................................................ភេទ...........អាយុ.............ឆ្នាំ ជនជាតិ.............
សញ្ជាតិ....................ទីលំនៅបច្ចុប្បន្នផ្ទះលេខ.......................ផ្លូវលេខ.................ក្រុមទី.................................
ភូមិ........................ឃុំ-សង្កាត់................................ ក្រុង -ស្រុក.......................ខេត្ត ............................
អត្តសញ្ញាណប័ណ្ណ ឬ ប័ណ្ណគ្រួសារ..........................................មុខរបរ..................................................

**សូមគោរពជូន**

**លោកអភិបាលក្រុង -ស្រុក**

**កម្មវត្ថុ :** សំណើសុំលិខិតអនុញ្ញាតទោចក្រយានយន្តសណ្តោងរ៉ឺម៉កឬត្រីចក្រយានយន្តធ្វើអាជីវកម្មដឹកជញ្ជូន ដោយខ្ញុំបាទទើបទិញ(១) ...........................................................០១គ្រឿង ( មួយគ្រឿង) ដែលមាន

ពិនភាគដូចខាងក្រោម :

- ម៉ាក ........................................................ ប្រភេទ (២) ..................................................
- លេខសាក់ស៊ី.................................................. លេខតួ.......................................................

លេខម៉ាស៊ីន................................................ កម្លាំងសេះ.................................................

- ពណ៌ ....................... ផ្លាកលេខទោចក្រយានយន្ត ឬត្រីចក្រយានយន្ត................................
- ផ្លាកលេខរ៉ឺម៉កសណ្តោង.................................ទំងន់ទទេ...................................................
- ទម្ងន់ ឬចំណុះផ្ទុក......................................... ទម្ងន់សរុប................................................
- ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬត្រីចក្រយានយន្តធ្វើអាជីវកម្មដឹក(៣) ...............................

ទិសដៅធ្វើអាជីវកម្មដឹក(៣) ..........................................................................................

អ្នកបើកបរឈ្មោះ........................................ មានទីលំនៅ..................................................

ក្រុមទី...........ឃុំ-សង្កាត់.................. ក្រុង -ស្រុក........................ខេត្ត .............................

ប័ណ្ណបើកបរលេខ.........................................................................................................

អាស្រ័យហេតុនេះ សូម **លោកអភិបាលក្រុង-ស្រុក** មេត្តាផ្តល់លិខិតអនុញ្ញាតឱ្យទោចក្រយានយន្តសណ្តោងរ៉ឺម៉កឬត្រីចក្រយានយន្តខ្ញុំបាទបានធ្វើអាជីវកម្មដឹកជញ្ជូនដល់ខ្ញុំដោយ អនុគ្រោះ។

សូម **លោកអភិបាលក្រុង-ស្រុក** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

....................ថ្ងៃទី........ខែ...........ឆ្នាំ២០១...

ហត្ថលេខា

**ជូនភ្ជាប់មកជាមួយ**

-ប័ណ្ណសំគាល់យានយន្ត

-លិខិតពន្ធដា( ប៉ាតង់)

-សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត

(១) បញ្ជាក់ថា : ទើបនឹងទិញ ឬ អំណោយ ឬ តម្លើងថ្មី.....................។

(២) បញ្ជាក់ថា : ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬត្រីចក្រយានយន្ត .........................។

(៣) បញ្ជាក់ថា : ដឹកអ្នកដំណើរ ឬ ដឹកទំនិញ ឬ ដឹកភ្ញៀវ ...។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និង ដឹកជញ្ជូន

## ឧបសម្ព័ន្ធទី ៥

យោង សេចក្តីណែនាំលេខ សក.សណន ចុះថ្ងៃទី ខែ ឆ្នាំ ២០១០ លើការអនុវត្តន៍
ប្រកាសស្តីពីការធ្វើប្រតិភូកម្មអំណាចរដ្ឋបាលកណ្តាល ពីក្រសួងសាធារណការ និងដឹកជញ្ជូន

## តារាងតម្លៃនៃការផ្តល់ប័ណ្ណគោចរក្រយានយន្ត

| បរិយាយ | ចុះបញ្ជីថ្មី | ប្តូរប័ណ្ណ | ប្តូរ ម៉ាស៊ីន-ពណ៌) | ទុតិយតាប័ណ្ណ | តតិយតា | ផ្ទេរកម្មសិទ្ធិ |
|---|---|---|---|---|---|---|
| | ម៉ូតូ | ម៉ូតូ | ម៉ូតូ | ម៉ូតូ | ម៉ូតូ | ម៉ូតូ |
| ពាក្យសុំ | ៤០០៛ | ៤០០៛ | ៤០០៛ | ៤០០៛ | ៤០០៛ | ៤០០៛ |
| សិទ្ធិចុះបញ្ជី | ១.០០០៛ | ១.០០០៛ | ១.០០០៛ | ២.៤០០៛ | ៣.៦០០៛ | ១.០០០៛ |
| តែមប្រិយ៍ | ៤.៥០០៛ | ៤.៥០០៛ | ៤.៥០០៛ | ៤.៥០០៛ | ៤.៥០០៛ | ៤.៥០០៛ |
| ផ្លាកលេខ | ៥.៧២$ | ៥.៧២$ | ៥.៧២$ | ៥.៧២$ | ៥.៧២$ | ៥.៧២$ |
| ប័ណ្ណសម្គាល់ | ៦.១៤៥$ | ៦.១៤៥$ | ៦.១៤៥$ | ៦.១៤៥$ | ៦.១៤៥$ | ៦.១៤៥$ |
| សេវាប្រតិបត្តិការ | ១៥.០០០៛ | ១៥.០០០៛ | ១៥.០០០៛ | ១៥.០០០៛ | ១៥.០០០៛ | ១៥.០០០៛ |
| **សរុប** | **២៥.៩០០៛** | **២០.៩០០៛** | **២០.៩០០៛** | **២២.៣០០៛** | **២៣.៥០០៛** | **២០.៩០០៛** |
| | **១១.៨៦៥$** | **១១.៨៦៥$** | **១១.៨៦៥$** | **១១.៨៦៥$** | **១១.៨៦៥$** | **១១.៨៦៥$** |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និង ដឹកជញ្ជូន

## ឧបសម្ព័ន្ធទី ៦

យោង សេចក្តីណែនាំលេខ សក.សណន ចុះថ្ងៃទី ខែ ឆ្នាំ ២០១០ លើការអនុវត្តន៍
ប្រកាសស្តីពីការធ្វើប្រតិភូកម្មអំណាចរដ្ឋបាលកណ្តាល ពីក្រសួងសាធារណការ និងដឹកជញ្ជូន

## តារាងតម្លៃនៃការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន
## តាមត្រីចក្រយានយន្ត និងរ៉ឺម៉កសណ្តោងដោយទោចក្រយានយន្ត

ឯកត្តា : រៀល + $

| បរិយាយ | ការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន | | ការបន្តលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន | |
|---|---|---|---|---|
| | ត្រីចក្រយានយន្ត | រ៉ឺម៉កសណ្តោងដោយទោចក្រយានយន្ត | ត្រីចក្រយានយន្ត | រ៉ឺម៉កសណ្តោងដោយទោចក្រយានយន្ត |
| ពាក្យសុំ | ៤០០៛ | ៤០០៛ | ៤០០៛ | ៤០០៛ |
| សិទ្ធិចុះបញ្ជី | ៣.០០០៛ | ២.០០០៛ | ៣.០០០៛ | ២.០០០៛ |
| តែមប្រិយ៍ | ២.០០០៛ | ២.០០០៛ | ២.០០០៛ | ២.០០០៛ |
| សេវាប្រតិបត្តិការ | ៨.០០០៛ | ៨.០០០៛ | ៨.០០០៛ | ៨.០០០៛ |
| **សរុប** | **១៣.៤០០៛** | **១២.៤០០៛** | **១៣.៤០០៛** | **១២.៤០០៛** |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

លេខ : ...០១០........ សក.សណន

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០១០...

# សេចក្តីណែនាំ

## ស្តីពីការអនុវត្តន៍ប្រកាស ស្តីពីការធ្វើប្រតិភូកម្មអំណាចរដ្ឋបាលកណ្តាល ពីក្រសួងសាធារណការ និងដឹកជញ្ជូន

## ជូនដល់

## ក្រុងតាខ្មៅនៃខេត្តកណ្តាល ក្រុងព្រះសីហនុនៃខេត្តព្រះសីហនុ ក្រុងស្ទឹងសែននៃខេត្តកំពង់ធំ ក្រុងសួងនៃខេត្តកំពង់ចាម ក្រុងក្រចេះនៃខេត្តក្រចេះ ក្រុងប៉ោយប៉ែតនៃខេត្តបន្ទាយមានជ័យ និងស្រុកពាមរក៍នៃខេត្តព្រៃវែង

ក្នុងគោលបំណងធានាការបង្កិតសេវាកម្មសាធារណៈលើវិស័យសាធារណការក្នុងក្របខ័ណ្ឌការងារថែទាំ ផ្លូវ ស្ពាន លូ ការសម្អាត មុខលូ ក្បាលស្ពាន ក្រោមស្ពាន ការសម្អាតចិញ្ចើមផ្លូវ ការទប់ស្កាត់ការរំលោភបំពានដីចំណីផ្លូវ និងលើវិស័យដឹកជញ្ជូន ក្នុងក្របខ័ណ្ឌការងារចុះបញ្ជីយានយន្ត និងការអនុញ្ញាតិធ្វើអាជីវកម្មដឹកជញ្ជូនឱ្យបានជិតប្រជាពលរដ្ឋនៅតាមមូលដ្ឋានចំពោះ **ក្រុងតាខ្មៅ នៃខេត្តកណ្តាល ក្រុងព្រះសីហនុ នៃខេត្តព្រះសីហនុ ក្រុងស្ទឹងសែន នៃខេត្តកំពង់ធំ ក្រុងសួង នៃខេត្តកំពង់ចាម ក្រុងក្រចេះ នៃខេត្តក្រចេះ ក្រុងប៉ោយប៉ែត នៃខេត្តបន្ទាយមានជ័យ និងស្រុកពាមរក៍ នៃខេត្តព្រៃវែង** សមស្របតាមស្មារតីនៃសេចក្តីសម្រេចលេខ ១២ សសរ របស់រាជរដ្ឋាភិបាលកម្ពុជាចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៨ ស្តីពីការបង្កើតការិយាល័យច្រកចេញ-ចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក ខណ្ឌ ក្រសួងសាធារណការ និងដឹកជញ្ជូន សូម ធ្វើការណែនាំអំពីនីតិវិធីនៃការចុះបញ្ជីទោចក្រយានយន្ត និងត្រីចក្រយានយន្តគ្រប់ប្រភេទ និងការផ្តល់ លិខិតអនុញ្ញាតធ្វើអាជីវកម្មដូចតទៅ ÷

## ជំពូក ១

## វិស័យដឹកជញ្ជូន

## ក្នុងក្របខ័ណ្ឌការងារចុះបញ្ជីទោចក្រយានយន្តនិងត្រីចក្រយានយន្ត និងការអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន

### I – លក្ខខ័ណ្ឌនៃការចុះបញ្ជីទោចក្រយានយន្ត និងត្រីចក្រយានយន្ត :

១- ទោចក្រយានយន្តឬត្រីចក្រយានយន្តដែលអាចធ្វើការចុះបញ្ជីសុំប័ណ្ណសម្គាល់ និងពាក់ផ្លាកលេខយានជំនិះបានលុះត្រាតែម្ចាស់ទោចក្រយានយន្តឬត្រីចក្រយានយន្តនោះបានបំពេញកាតព្វកិច្ចបង់ពន្ធនាំចូលត្រឹមត្រូវតាមច្បាប់ជាធរមានរួចរាល់ហើយ ។

២- ម្ចាស់ទោចក្រយានយន្ត ឬត្រីចក្រយានយន្ត ត្រូវមានអាស័យដ្ឋានអចិន្ត្រៃយ៍ពិតប្រាកដនៅក្នុង ក្រុងតាខ្មៅនៃ

ខេត្តកណ្តាល ឬ ក្រុងព្រះសីហនុនៃខេត្តព្រះសីហនុ ឬ ក្រុងស្ទឹងសែននៃខេត្តកំពង់ធំ ឬ ក្រុងសួងនៃខេត្តកំពង់ចាម ឬ ក្រុងក្រចេះនៃខេត្តក្រចេះ ឬ ក្រុងប៉ោយប៉ែតនៃខេត្តបន្ទាយមានជ័យ ឬ ស្រុកពាមរក៍នៃខេត្តព្រៃវែង។

៣- ទោចក្រយានយន្តឬត្រីចក្រយានយន្តមួយគ្រឿងអាចធ្វើការចុះបញ្ជីសុំប័ណ្ណសម្គាល់យានជំនិះ និងពាក់ផ្លាកលេខសម្គាល់យានជំនិះបានតែមួយលើកប៉ុណ្ណោះ និងត្រូវលុបចេញពីបញ្ជីការវិញនៅពេលដែលទោចក្រយានយន្ត ឬត្រីចក្រយានយន្តនោះត្រូវខូចប្រើប្រាស់លែងកើត។

៤- ប័ណ្ណសម្គាល់យានជំនិះនិងផ្លាកលេខសម្គាល់យានជំនិះ មានរូបភាពនិងសណ្ឋានតាមការកំណត់ ក្នុងអនុក្រឹត្យលេខ ០៧៧ អនក្រ.កប ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាលកម្ពុជា និងតាមខ្លឹមសារសារាចរណែនាំលេខ ០១ សក.សរ ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៤ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

## II – បែបបទ និងនីតិវិធីនៃការចុះបញ្ជីទោចក្រយានយន្ត និងត្រីចក្រយានយន្ត :

### ក – សំណុំលិខិតស្នើសុំប័ណ្ណសម្គាល់យានជំនិះ :

**ពាក្យសុំប័ណ្ណសម្គាល់យានជំនិះ** ត្រូវមានសេចក្តីប្រកាសអំពី ភិនភាគប័ណ្ណសម្គាល់យានជំនិះ ម៉ាក ប្រភេទ ពណ៌ ឆ្នាំផលិត កម្លាំងម៉ាស៊ីន ទំហំស៊ីឡាំង លេខតួ លេខម៉ាស៊ីន ចំនួនភ្លៅ ( Essieux) និងត្រូវមានបិទតែមប្រ៍យតាមការកំណត់របស់រដ្ឋដូចមានក្នុងគម្រូឧបសម្ព័ន្ធទី១ ។ ( **គម្រូក្នុងឧបសម្ព័ន្ធទី១** )

ក្នុងពាក្យសុំប័ណ្ណសម្គាល់យានជំនិះនីមួយៗត្រូវមានភ្ជាប់ ÷

- អត្តសញ្ញាណប័ណ្ណ ឬលិខិតសម្គាល់ខ្លួនថតចម្លងរបស់អ្នកទិញ ដែលមានសុពលភាពមួយសន្លឹក
- បង្កាន់ដៃពន្ធនាំចូលច្បាប់ដើមមួយសន្លឹកដែលមានបញ្ជាក់ភាពត្រឹមត្រូវពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករស្រាប់
- វិក័យបត្រលក់យានជំនិះមួយសន្លឹក
- និង ឯកសារពាក់ពន្ធ័ផ្សេងៗប្រសិនមាន ។

### ខ – បែបបទនៃការចុះបញ្ជី :

### ១ – ភារកិច្ចរបស់ម្ចាស់ទោចក្រយានយន្ត និងត្រីចក្រយានយន្ត :

-ម្ចាស់ទោចក្រយានយន្ត ឬត្រីចក្រយានយន្តត្រូវបំពេញពាក្យសុំ និងបំពេញបែបបទសំណុំឯកសារ នៃពាក្យស្នើសុំដោយផ្ទាល់ដៃនិងចុះហត្ថលេខាទទួលខុសត្រូវលើពាក្យស្នើសុំឱ្យបានត្រឹមត្រូវតាមទម្រង់ច្បាប់។

-ម្ចាស់ទោចក្រយានយន្ត ឬត្រីចក្រយានយន្តត្រូវដាក់ពាក្យសុំប័ណ្ណសម្គាល់យានជំនិះ នៅការិយាល័យច្រកចេញ-ចូលតែមួយតាមក្រុង ឬស្រុកដោយនាំមកជាមួយនូវទោចក្រយានយន្តឬត្រីចក្រយានយន្តឱ្យមន្ត្រីដឹកជញ្ជូនធ្វើការត្រួតពិនិត្យភិនភាគលក្ខណៈបច្ចេកទេសជូន ។

### ២ – ភារកិច្ចរបស់មន្ត្រីដឹកជញ្ជូន

- មន្ត្រីទទួលពាក្យស្នើសុំត្រូវធ្វើការត្រួតពិនិត្យសំណុំបែបបទ នៃពាក្យស្នើសុំដែលមានចែងក្នុងចំណុច ក ខាងលើ

- ក្នុងករណីសំណុំពាក្យស្នើសុំមានលក្ខណៈគ្រប់គ្រាន់ដែលអាចទទួលយកបានមន្ត្រីទទួលពាក្យសុំ ត្រូវអញ្ជើញមន្ត្រីទទួលបន្ទុកដឹកជញ្ជូនទៅពិនិត្យមើលភិនភាគនិងលក្ខណៈបច្ចេកទេសរបស់ទោចក្រយានយន្ត ឬត្រីចក្រយានយន្ត ÷

✱ -**លេខតួ និងលេខម៉ាស៊ីន** : ជាលេខ ឬអក្សរដែលមានជាប់នៅនឹងតួ និងម៉ាស៊ីនដែលគេបានបោះពុម្ពពីរោងចក្រផលិត និងមានចុះក្នុងបង្កាន់ដៃពន្ធនាំចូល ។ លេខតួ និងលេខម៉ាស៊ីនរបស់ទោចក្រយានយន្តឬត្រីចក្រយានយន្ត គឺជាលេខតែមួយដូចគ្នានឹងលេខដែលចុះក្នុងបង្កាន់ដៃពន្ធនាំចូល។ មិនអនុញ្ញាតឱ្យកែឬលុប

លេខឬដាប់លេខបន្ថែមឬចុះខូះលេខណាមួយផ្ទុយពីលក្ខណៈដើមនៃទោចក្រយានយន្ត ឬត្រីចក្រយានយន្តឡើយ ។ លេខតួ និងលេខម៉ាស៊ីនត្រូវកាល់បិទភ្ជាប់នឹងពាក្យស្នើសុំចុះបញ្ជី

- -**ពណ៌** : គឺជាពណ៌ពិតប្រាកដដែលម្ចាស់ឃ្លាំងលក់ទោចក្រយានយន្ត ឬត្រីចក្រយានយន្ត បានបញ្ជាក់នៅក្នុង វិក័យប័ត្រ ទិញ-លក់
- -**ម៉ាក និងប្រភេទទោចក្រយានយន្តឬត្រីចក្រយានយន្ត** : គឺជាសញ្ញាសម្គាល់ទោចក្រយានយន្តឬត្រីចក្រយានយន្តនិងមានបញ្ជាក់នៅក្នុងបង្កាន់ដៃពន្ធនាំចូល ។

ក្រោយពេលដែលការត្រួតពិនិត្យលក្ខណៈនិងគិនភាគបានត្រឹមត្រូវរួចហើយមន្ត្រីទទួលបន្ទុកដឹកជញ្ជូនត្រូវបញ្ជូនឯកសារនេះទៅមន្ត្រីទទួលខុសត្រូវពិនិត្យ សម្រេច និងអនុញ្ញាតឱ្យធ្វើការចុះបញ្ជីនិងបំពាក់ផ្លាកលេខ ។

-មន្ត្រីជំនាញត្រូវយកផ្លាកលេខទោចក្រយានយន្ត ឬត្រីចក្រយានយន្តទៅបំពាក់ជាប់នឹងទោចក្រយានយន្ត ឬត្រីចក្រយានយន្ត ដោយប្រើប្រាស់ខ្មៅចាប់ភ្ជិតដែលមិនអាចដោះចេញបានដោយងាយ ។

-មន្ត្រីទទួលពាក្យស្នើសុំត្រូវចេញបង្កាន់ដៃទទួលពាក្យបណ្តោះអាសន្នមួយជូនម្ចាស់ទោចក្រយានយន្ត ដោយកំណត់ពេលវេលាមកទទួលយកប័ណ្ណសម្គាល់យានជំនិះពេញសិទ្ធិ នៅក្នុងរយៈពេលមិនលើសពី ១៥ ថ្ងៃ នៃថ្ងៃធ្វើការឡើយ ។

**៣ – ភារកិច្ចរបស់មន្ត្រីទទួលខុសត្រូវ :**

-ក្រោយពេលសំណុំឯកសារ នៃពាក្យស្នើសុំបានបញ្ជូនមកដល់មន្ត្រីទទួលខុសត្រូវរួចហើយ មន្ត្រីទទួលខុសត្រូវនោះត្រូវចុះហត្ថលេខាសម្រេចលើសំណុំឯកសារដើម្បីឱ្យមន្ត្រីជំនាញធ្វើការកត់ត្រា និងចុះបញ្ជីលេខសម្គាល់យានជំនិះក្នុងសៀវភៅចុះបញ្ជីយានជំនិះដូចមានក្នុងគម្រូឧបសម្ព័ន្ធទី ២ ។ (**គម្រូក្នុងឧបសម្ព័ន្ធទី២** )

-ក្រោយការចុះបញ្ជីការរួចរាល់ហើយ សំណុំឯកសារនៃពាក្យស្នើសុំទាំងអស់ត្រូវរៀបចំជាតារាងបញ្ជីរាយនាមអ្នកសុំធ្វើប័ណ្ណសម្គាល់យានជំនិះដែលត្រូវផ្តល់ជូនម្ចាស់កម្មសិទ្ធិយានយន្តដូចមានក្នុងគម្រូ( **ឧបសម្ព័ន្ធទី៣** ) តាមប្រព័ន្ធកុំព្យូទ័រ ដោយចងក្រងចំនួន ១០ គ្រឿងយ៉ាងច្រើនក្នុងតារាងនីមួយៗដោយមានចុះហត្ថលេខាទទួលខុសត្រូវរបស់មន្ត្រីចុះបញ្ជីយានយន្ត( មន្ត្រីទទួលបន្ទុកដឹកជញ្ជូន) ប្រធានការិយាល័យច្រកចេញ-ចូលតែមួយ និងអភិបាលក្រុង ឬអភិបាលស្រុក ហើយត្រូវបញ្ជូនមកមន្ទីរសាធារណការ និងដឹកជញ្ជូននៃខេត្តសាមីដើម្បីផលិតប័ណ្ណសម្គាល់យានជំនិះជូន ដូចមានក្នុងគម្រូឧបសម្ព័ន្ធទី ៣ ។ (**ឧបសម្ព័ន្ធទី ៣** )

**គ – លក្ខណៈមិនប្រក្រតីនៃទោចក្រយានយន្ត និងត្រីចក្រយានយន្ត :**

១-ទោចក្រយានយន្ត ឬត្រីចក្រយានយន្ត ដែលមានភាពមិនប្រក្រតីត្រូវធ្វើការត្រួតពិនិត្យដោយឡែកពីគណៈកម្មការបច្ចេកទេសមួយដើម្បីធ្វើការវាយតម្លៃជាមុនសិន ទើបធ្វើការចុះបញ្ជីនិងចេញប័ណ្ណសម្គាល់យានជំនិះជូនដល់ទោចក្រយានយន្ត ឬត្រីចក្រយានយន្តទាំងនោះបាន ។

២-ទោចក្រយានយន្តឬត្រីចក្រយានយន្តមានលក្ខណៈបច្ចេកទេសមិនប្រក្រតី គឺជាទោចក្រយានយន្ត ឬត្រីចក្រយានយន្តដែលមានលេខតួ ឬលេខម៉ាស៊ីនរលុប ពណ៌ខុសប្រក្រតី ប្តូរម៉ាស៊ីន ឬផ្សារតួ រលុបបាត់លេខតួមើលមិនឃើញច្បាស់ ។ លក្ខណៈមិនប្រក្រតីនេះរមែងកើតឡើងអំពីភាពចាស់សឹករេចរឹល ឬដោយមូលហេតុគ្រោះថ្នាក់ចរាចរ ឬដោយប្រការណាមួយផ្សេងទៀត ។

៣-ក្នុងករណីមានភាពមិនប្រក្រតីខាងលើនេះ ការសម្រេចពាក់ផ្លាកលេខ និងចុះបញ្ជីមិនត្រូវអនុញ្ញាតឱ្យធ្វើដោយប្រញាប់ប្រញាល់ឡើយ លើកលែងតែអ្នកបច្ចេកទេសបានវាយតម្លៃពីភាពត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសកំណត់និងមានកំណត់ហេតុបញ្ជាក់ពីមូលហេតុច្បាស់លាស់នៃភាពមិនប្រក្រតីទាំងនោះ ។

ឃ- ករណីហាមឃាត់ :

១- មិនអនុញ្ញាតឱ្យធ្វើការចុះបញ្ជី និងផ្តល់ផ្លាកលេខសម្គាល់យានជំនិះចំពោះទោចក្រយានយន្ត ឬត្រីចក្រយានយន្ត ដែលពុំបានបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវ ឬគ្មានបង្កាន់ដៃពន្ធនាំចូល ឬបង្កាន់ដៃពន្ធសរសេរបន្ថែម ឬថតចម្លងគ្មានការបញ្ជាក់ទទួលខុសត្រូវពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករឡើយ ។

២- មិនអនុញ្ញាតឱ្យធ្វើការចុះបញ្ជី និងផ្តល់ផ្លាកលេខសម្គាល់យានជំនិះចំពោះទោចក្រយានយន្ត ឬត្រីចក្រយានយន្ត ទាំងឡាយណាដែលមានលេខតួ ឬលេខម៉ាស៊ីនដាប់ដោយម្ចាស់មធ្យោបាយផ្ទាល់ និងដោយគ្មានមូលហេតុត្រឹមត្រូវ ។

៣- ករណីធ្វើការចុះបញ្ជី និងផ្តល់ផ្លាកលេខសម្គាល់យានជំនិះ ចំពោះទោចក្រយានយន្ត ឬត្រីចក្រយានយន្ត ដែលមានភាពមិនប្រក្រតី ក្នុងចំណុច ២ ខាងលើនេះ សាលាក្រុង-ស្រុកទាំងអស់ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។

ង- ទោចក្រយានយន្ត ឬត្រីចក្រយានយន្តកែច្នៃ ឬតម្លើង :

ទោចក្រយានយន្ត ឬត្រីចក្រយានយន្តកែច្នៃ ឬតម្លើងថ្មី មិនត្រូវបានអនុញ្ញាតឱ្យការិយាល័យច្រកចេញ-ចូលតែមួយរបស់សាលាក្រុង-ស្រុក ធ្វើការចុះបញ្ជីឡើយទោះបីជាបានបំពេញកាតព្វកិច្ចបង់ពន្ធរួចហើយក្តី ពីព្រោះមានពាក់ពន្ធនឹងផ្នែកបច្ចេកទេស និងសុវត្ថិភាពយានយន្ត ។ ក្នុងករណីនេះត្រូវណែនាំឱ្យម្ចាស់យានយន្តទៅទំនាក់ទំនងជាមួយមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ធ្វើការចុះបញ្ជីជូនដោយឡែក ។

III – ការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន :

១- ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ត្រីចក្រយានយន្តមុននឹងដាក់ដំណើរការធ្វើអាជីវកម្មដឹកជញ្ជូនត្រូវមានលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនដែលចេញដោយការិយាល័យច្រកចេញ-ចូលតែមួយរបស់សាលាក្រុង-ស្រុក ដែលម្ចាស់កម្មសិទ្ធិមានទីលំនៅអចិន្ត្រៃយ៍ស្នាក់នៅ ។

២- សំណុំលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនមានពាក្យសុំមួយច្បាប់មានបិទតែមប្រើយត្រឹមត្រូវដោយមានបញ្ជាក់អំពីកម្មវត្ថុដឹកជញ្ជូនទិសដៅដឹកជញ្ជូននិងសមត្ថភាពដឹកជញ្ជូនច្បាស់លាស់ ដូចមានក្នុងគម្រូឧបសម្ព័ន្ធទី៤។ (**ឧបសម្ព័ន្ធទី ៤**)

ក្នុងពាក្យសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនមានពាក្យសុំមួយច្បាប់ត្រូវមានភ្ជាប់នូវ ÷

- វិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេស
- ប័ណ្ណសម្គាល់យានជំនិះ
- បង្កាន់ដៃបង់សិទ្ធិប្រកបអាជីវកម្មដឹកជញ្ជូន
- និងលិខិតផ្សេងៗទៀតដែលពាក់ព័ន្ធ។

៣- ការិយាល័យច្រកចេញ-ចូលតែមួយរបស់សាលាក្រុង-ស្រុក មានសមត្ថកិច្ចចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនចំពោះមធ្យោបាយដឹកជញ្ជូន ដែលប្រកបអាជីវកម្មនៅក្នុងរង្វង់ក្រុង-ស្រុករបស់ខ្លួន និងមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យសកម្មភាពដឹកជញ្ជូន ឬត្រូវដកហូតសិទ្ធិប្រកបអាជីវកម្មដឹកជញ្ជូន បើពិនិត្យឃើញថាសកម្មភាពដឹកជញ្ជូនខុស អំពីគោលការណ៍នៃច្បាប់ ។

IV – អំពីតម្លៃសេវាកម្ម :

តម្លៃសេវាកម្ម និងតម្លៃនៃពាក្យសុំប័ណ្ណសម្គាល់យានជំនិះ និង តម្លៃសេវាកម្ម និងតម្លៃនៃពាក្យសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនត្រូវអនុវត្តតាមតារាងឧបសម្ព័ន្ធទី ៥ និងតារាងឧបសម្ព័ន្ធទី ៦ នៃសេចក្តីណែនាំនេះ ។ (**ឧបសម្ព័ន្ធទី ៥ និង ឧបសម្ព័ន្ធទី ៦**)

# ជំពូក ២

## វិស័យសាធារណការ

## ក្នុងក្របខណ្ឌការងារថែទាំ ការសម្អាតផ្លូវ ស្ពាន លូ ចិញ្ចើមផ្លូវ

## និងការទប់ស្កាត់ការរំលោភបំពានដីចំណីផ្លូវ

I – ការងារថែទាំផ្លូវ ( គ្រួសក្រហម ) :

**ក -ការងារថែទាំត្រួសផ្លូវ ឬមុខផ្លូវ :**

❖ - សម្ភារៈប្រើប្រាស់គឺសាមញ្ញ អាចរកបាននៅមូលដ្ឋាន ដូចជា គ្រួសក្រហម ត្រសេះ ចបកាប់ បង្គី ប៉ែល ជើងដំរី ធុងស្រោចទឹក រហូតដល់ម៉ាស៊ីនបង្ហាប់ ( Jumping ) រ៉ូឡូ ទម្ងន់ ៧៥០ គ.ក្រ ( Roller 750 kg ) ជាដើម ។ល។

❖ - វិធីអនុវត្តន៍ និងការប្រើប្រាស់សម្ភារៈត្រូវសមស្របទៅ នឹងទំហំការខូចនៃផ្លូវ :

១-ចំពោះផ្ទៃផតដែលមានរាងជាសំបុកមាន់ មានទំហំ តូច ឬ ធំជាង ត្រូវប្រើត្រសេះ (ឬចបកាប់) ចរជារណ្តៅជារាងបួនជ្រុងស្មើ ឬទ្រវែង ( ដើម្បីកុំឱ្យសម្ភារៈដែលចាក់បំពេញថ្មី រអិលចេញពីផ្ទៃចាស់បាន ) បន្ទាប់មកសម្អាតរណ្តៅដែលចររួចចាក់បំពេញសម្ភារៈថ្មី (គ្រួសក្រហម) ទៅក្នុងរណ្តៅស្រោចទឹកឱ្យសើមល្មម ហើយបង្ហាប់ដោយជើងដំរី ឬដោយម៉ាស៊ីនបុក បង្ហាប់ (Jumping) ឱ្យហាប់ជាស្រទាប់ៗរហូតស្មើផ្ទៃថ្នល់ ។

២-ចំពោះផ្ទៃដែលមានសណ្តានជារលកទទឹងផ្ទៃស្រុតផត មានទ្រង់ទ្រាយធំជ្រៅដែលតម្រូវឱ្យមានការប្រើប្រាស់គ្រឿងចក្រធុនធ្ងន់ដើម្បីជីកកាយ គៀរ និងកិនបង្ហាប់តាមបច្ចេកទេសនោះ វាអាស្រ័យលើទំហំការងារ និងលទ្ធភាព ។

**ខ -ការងារថែទាំចិញ្ចើម និងជើងទេ :**

១-លុបចង្អូរនៅចុងចិញ្ចើមផ្លូវដែលហូរច្រោះដាច់ដោយទឹកដោយប្រើសម្ភារៈ ( គ្រួសក្រហម) និងវិធីធ្វើដូចលុបមុខផ្លូវដែរ ។

២-លុបចង្អូរលើជើងទេរដែលហូរច្រោះដាច់ដោយទឹក (ជាទូទៅបន្តពីចុងចិញ្ចើម) ដោយដីធម្មតាជាពិសេសដីដែលងាយដុះស្មៅ ។

៣-សម្អាតព្រៃស៊ុបទ្រុបនៅអមសងខាងផ្លូវឱ្យស្រឡះ ដើម្បីបញ្ចៀសឧបសគ្គដែលបណ្តាលមកពីការមើលមិនឃើញ ។

II – ការថែទាំផ្លាកសញ្ញា :

១-ផ្លាកសញ្ញាដែលមានត្រូវ ថែទាំមិនឱ្យវៀច ទ្រេត ឬរលំបង្គោល មិនឱ្យរលុប បែរមុខខុសទិស និងបាត់បង់ ផ្លាក ។

២-ករណីខ្វះ មិនគ្រប់គ្រាន់តាមតម្រូវការចាំបាច់ត្រូវលើកគម្រោងស្នើសុំបំពាក់បន្ថែមជាជំហានៗ ។

III – ការថែទាំស្ពាន-លូ :

១-ធ្វើការសម្អាតឱ្យបានទាន់ពេលនូវសំរាម កម្ទេចកម្ទី ពំនូកដី ។ល។ ដែលគរឬកកតាមមុខតំណរ ស្ពាន-លូ លើ ស្ពាន-លូ ដោយធ្វើយ៉ាងណាពេលរាំងភ្លៀង គឺអស់ទឹកពីលើស្ពាន-លូ ។

២-ព្រៃ សំរាម កំណាត់ផ្សេងៗ ។ល។ ដែលជុះឬកកតាមក្បាលមុខ និងក្នុងស្ពាន-លូ ត្រូវកាប់ឆ្ការ និងយកចេញឱ្យអស់ ជាពិសេសមុនរដូវវស្សាចូលមកដល់ ។

៣-ការបាក់បែកបន្តិចបន្តួចដែលមិនទាមទារបច្ចេកទេសចាំបាច់ត្រូវធ្វើការថែទាំ ឬម្ចាស់ការជួសជុលស្ពាន-លូទាំងនោះឱ្យ បានទាន់ពេល ។

**សេចក្តីបញ្ជាក់ :**

ចំពោះគម្រោងការងារជួសជុលធំការងារស្ពាន ឬកសាងថ្មីដែលទាមទារថវិកាច្រើន បច្ចេកទេសខ្ពស់ប្រធានការិយាល័យស្រុក ដែលទើបនឹងធ្វើប្រតិភូកម្មអំណាចថ្មីត្រូវទៅចូលរួមជាមួយមន្ទីរកណ្តាល( ការិយាល័យសាធារណការ) ក្នុងការលើកគម្រោងស្នើ សុំថវិកាទៅថ្នាក់ខេត្ត ឬថ្នាក់រាជរដ្ឋាភិបាល ប្រចាំឆ្នាំ ឬ ៥ ឆ្នាំ ជាការចាំបាច់ និងខានពុំបាន ។

ទទួលបាននូវសេចក្តីណែនាំនេះអភិបាលក្រុងតាខ្មៅ នៃខេត្តកណ្តាល អភិបាលក្រុងព្រះសីហនុ នៃខេត្តព្រះសីហនុ អភិបាលក្រុងស្ទឹងសែន នៃខេត្តកំពង់ធំ អភិបាលក្រុងសួង នៃខេត្តកំពង់ចាម អភិបាលក្រុងក្រចេះ នៃខេត្តក្រចេះ អភិបាល ក្រុងប៉ោយប៉ែត នៃខេត្តបន្ទាយមានជ័យ និងអភិបាលស្រុកពាមរក៍ នៃខេត្តព្រៃវែង ត្រូវសហការជាមួយមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តសាមី អគ្គនាយកដ្ឋានសាធារណការ អគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការនិងដឹកជញ្ជូន និងអាជ្ញាធរ មានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ដើម្បីមានវិធានការជាក់ស្តែង និងទទួលការណែនាំបន្ថែមទៀតក្នុងការអនុវត្តន៍សេចក្តីណែនាំនេះឱ្យ មានប្រសិទ្ធិភាពខ្ពស់ ។

រដ្ឋមន្ត្រី

ត្រាំ អ៊ីវទឹក

**ចម្លងជូន**

- ក្រសួងមហាផ្ទៃ
- សាលា ខេត្តកណ្តាល ខេត្តព្រះសីហនុ ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តក្រចេះ ខេត្តបន្ទាយមានជ័យ និងខេត្តព្រៃវែង

"**ដើម្បីជ្រាបជាពត៌មាន**"

- អគ្គនាយកដ្ឋានសាធារណការ
- អគ្គនាយកដ្ឋានដឹកជញ្ជូន
- មន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកណ្តាល ខេត្តព្រះសីហនុ ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តក្រចេះ ខេត្តបន្ទាយមានជ័យ និងខេត្តព្រៃវែង

"**ដើម្បីតាមដានការអនុវត្តន៍**"

- ឯកសារ-កាលប្បវត្តិ